**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ប្រាក់ចំណូលគយឈានដល់ជិត ២.៣ ប៊ីលានដុល្លារក្នុងឆ្នាំ ២០២១
- ថវិកាបន្ថែម ១០០លានដុល្លារ ដើម្បីគាំទ្រសហគ្រាស ធុន តូច និងមធ្យម និងវិស័យកសិកម្ម
- រដ្ឋាភិបាលផ្ដើមសាកល្បងអនុវត្តកម្មវិធីធានារ៉ាប់រងដំណាំស្រូវដល់កសិករ ប៉ះពាល់ដោយភ្លៀង ឬជំនន់
- ប្រធានសភាកូរ៉េខាងត្បូង សន្យាពន្លឿននីតិវិធី ផ្តល់សច្ចាប័នកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ
- សេដ្ឋកិច្ចជប៉ុនស្ទុះងើបឡើងវិញដោយសារតម្រូវការបន្ទឹងមាំបើទោះបីមានការរីករាលដាលនៃវីរុសអូមីក្រុង
- ក្រុមហ៊ុនអាមេរិកស្នើអាជ្ញាធរយកពន្ធនាំចូលបន្ទះសូឡាពីប្រទេសអាស៊ីអាគ្នេយ៍ចំនួន៤រួមទាំងកម្ពុជា
- រដ្ឋមន្ត្រីក្រសួងថាមពលតំណាងប្រទេសអេហ្ស៊ីប និងស៊ីប បង្ហាញនូវការព្រួយបារម្ភអំពីការកើនឡើងតម្លៃប្រេងទៅលើសពី ១០០ដុល្លារអាមេរិក ក្នុងមួយបារ៉ែល
- ការលក់បន្ទះឈីបសកល បំបែកកំណត់ត្រាខ្ពស់បំផុតក្នុងឆ្នាំ២០២១ ខណៈ ការលក់នឹងកើនឡើង ៨,៨% នៅឆ្នាំ២០២២
- តើគោលនយោបាយគ្មានកូវីដ១៩របស់ចិន ពិតជាកំពុងគំរាមកំហែង ដល់កំណើនសេដ្ឋកិច្ចពិភពលោក?
- តើកត្តាអ្វីខ្លះជំរុញឱ្យតម្លៃទំនិញសកលលោកកើនឡើង ៥០% ជាកំណើនខ្ពស់បំផុតក្នុងរយៈពេល ២៧ ឆ្នាំចុងក្រោយនេះ?


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ប្រាក់ចំណូលគយឈានដល់ជិត ២.៣ ប៊ីលានដុល្លារក្នុងឆ្នាំ ២០២១




*ប្រភព៖ Hong Phanet, Phnom Penh Post ២០២២*

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (GDCE) ប្រមូលចំណូលបាន ៩,២៩៥៧ ទ្រីលានរៀល (២,២៩៥ ប៊ីលានដុល្លារ) កាលពីឆ្នាំមុន ធ្លាក់ចុះ ៥,១%ពី ២,៤១៩ ប៊ីលានដុល្លារក្នុងឆ្នាំ ២០២០។ ខណៈពេលដែល ប្រាក់ចំណូលគយសរុបក្នុងឆ្នាំ២០២១ នេះ សម្រេចបានក្នុងអត្រា ៩៧.១% នៃគោលដៅដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២១។

ប្រភពចំណូលគយ និងរដ្ឋាករច្រើនជាងគេគឺ យានជំនិះ និងគ្រឿងចក្រ (៣.៩៩៨៨ទ្រីលានរៀល ស្មើរនឹង ៤៣%) និងផលិតផលគីមីឥន្ទនៈ ២.១៥៧១ទ្រីលានរៀល ស្មើរនឹង២៣.២% ដោយសម្ភារសំណង់ និងផលិតផលផ្សេងទៀតមានជិត ៣.១៤ ទ្រីលានរៀល ស្មើរនឹង៣៣.៨% ។

ជាមួយគ្នានេះ ការនាំចេញផលិតផលកាត់ដេរមាន ១១ ៣៨៩.៦ លានដុល្លារ កើនឡើង ១៥.២% ខណៈការនាំចេញផលិតផលវិនិយោគមិនមែនកាត់ដេរ មាន ៤ ៩៤២.១ លានដុល្លារ កើនឡើង៤៤.២% និងកសិផល ២ ៨១៧.៨ លានដុល្លារ កើនឡើង ៣៩.៥%។

ទោះបីចំណូលគយធ្លាក់ចុះក៏ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលើកឡើងពីតួលេខកាលពីឆ្នាំមុនថាជា"លទ្ធផលល្អ" ដោយសារហានិភ័យខ្ពស់នៃការរីករាលដាលជំងឺកូវីដ១៩ដែលកើតមានក្នុងឆ្នាំ ២០២១ ហើយបន្តលើកកម្ពស់ "ការអនុវត្តដ៏តឹងរ៉ឹង និងមានប្រសិទ្ធភាព" នៃការប្រមូលពន្ធ និងសម្របសម្រួលជាមួយអាជ្ញាធរពាក់ព័ន្ធ លើវិធានការបង្ការប្រឆាំងនឹងការគេចពន្ធ។*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ Phnom Penh Post ចេញផ្សាយថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១*

## ថវិកាបន្ថែម ១០០លានដុល្លារ ដើម្បីគាំទ្រសហគ្រាសធុន តូច និងមធ្យម និងវិស័យកសិកម្ម




*ប្រភព៖ Chea Vanyuth, Khmer Times ២០២២*

រដ្ឋាភិបាល បានត្រៀមថវិកាចំនួន ១០០លានដុល្លារ ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម វិស័យកសិកម្ម និងកសិឧស្សាហកម្ម ដែលអាចឱ្យអាជីវកម្មរបស់ពួកគេងើបឡើងវិញក្នុងពេលនៃជំងឺរាតត្បាត។

ថវិកានេះ គឺជាកម្មវិធីបន្ទាន់ពិសេសដែលរាជរដ្ឋាភិបាលផ្តល់ដល់វិស័យឯកជនតាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម របស់រដ្ឋចំនួនពីរ និងធនាគារ SME Bank ដើម្បីគាំទ្រដល់ការស្តារកំណើនសេដ្ឋកិច្ចឡើងវិញ

បន្ទាប់ពីវិបត្តិជំងឺកូវីដ១៩ ដែលជាផ្នែកមួយនៃការស្តារកំណើនសេដ្ឋកិច្ចកម្ពុជានាពេលខាងមុខ ជាពិសេសដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រ ក្របខណ្ឌ និងកម្មវិធីដើម្បីស្តារ និងលើកកម្ពស់កំណើនសេដ្ឋកិច្ចកម្ពុជាដើម្បីរស់នៅតាមប្រក្រតីថ្មីសម្រាប់ឆ្នាំ២០២១-២០២៣។ ជាមួយគ្នានេះ ថវិកានេះ នឹងបែងចែកជាពីរផ្នែក គឺ ៥០លានដុល្លារសម្រាប់ធនាគារកសិកម្ម និងអភិវឌ្ឍន៍ជនបទ និង ៥០លានដុល្លារសម្រាប់ធនាគារ SME ដើម្បីប្រើប្រាស់សម្រាប់គាំទ្រសកម្មភាពរបស់សហគ្រាសធុនតូច និងមធ្យមដែលត្រូវការជំនួយ និងគាំទ្រដល់វិស័យស្រូវអង្ករ ការចិញ្ចឹមសត្វ ផលិតកម្មដំណាំរបស់កម្ពុជា ក៏ដូចជាគាំទ្រយន្តការសហហិរញ្ញប្បទានចែករំលែកហានិភ័យជាមួយធនាគារ និងស្ថាប័នហិរញ្ញវត្ថុ។

ទន្ទឹមនឹងនេះ រដ្ឋាភិបាលកម្ពុជា បានចាត់ទុកការជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ជាពិសេសសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យសំខាន់ៗដូចជាកសិកម្ម កសិឧស្សាហកម្ម កែច្នៃចំណីអាហារ សមាសភាគ ទេសចរណ៍ ជាអាទិភាពគោលនយោបាយសំខាន់។ ហើយសហគ្រាសធុនតូច និងមធ្យម មានប្រមាណ ៩៨% នៃអាជីវកម្មទាំងអស់នៅក្នុងប្រទេសកម្ពុជា ហើយរួមចំណែកប្រមាណ ៥៨%នៃផ.ស.ស និងផ្តល់ការងារប្រហែល៧៣%នៃកម្លាំងពលកម្មសរុបនៅកម្ពុជា។

នៅឆ្នាំ២០២១ រាជរដ្ឋាភិបាល បានផ្តួចផ្តើមដំណាក់កាលទី១ នៃកម្មវិធីសហហិរញ្ញប្បទាន តាមរយៈធនាគារ SME ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងទំហំទឹកប្រាក់សរុបចំនួន ១០០លានដុល្លារ ដែលរាជរដ្ឋាភិបាលបានបរិច្ចាគចំនួន ៥០លានដុល្លារ ហើយនៅសល់ពីគ្រឹះស្ថានហិរញ្ញវត្ថុឯកជន។ ហើយដំណាក់កាលទីពីរ ត្រូវបានចាប់ផ្តើមនៅក្នុងខែសីហា ឆ្នាំ២០២១ ជាមួយនឹងថវិកាចំនួន ១៥០លានដុល្លារ ដែលក្នុងនោះជាង ៧០លានដុល្លារត្រូវបានចូលរួមចំណែកដោយរាជរដ្ឋាភិបាល និងមួយទៀត ត្រូវបានផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុ។

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២*

## កម្ពុជា ចំណាយថវិកាជាង ១០០លានដុល្លារ ទិញអគ្គីសនីពីឡាវ ក្នុងមួយឆ្នាំ



*ដោយ Kampucheathmey*

ប្រធានអគ្គិសនីកម្ពុជា បានបញ្ជាក់ថា បច្ចុប្បន្ននេះកម្ពុជា បានចំណាយថវិកាទិញអគ្គិសនីពីប្រទេសឡាវ ប្រមាណជាង ១០០លានដុល្លារ ក្នុង១ឆ្នាំ ដើម្បីផ្គត់ផ្គង់ភ្លើងក្នុងស្រុក។ ក្រៅពីប្រទេសឡាវ កម្ពុជា ក៏ទិញអគ្គិសនីពីប្រទេសថៃ និងវៀតណាមផងដែរ។ កម្រិតនៃការទិញអគ្គិសនីពីក្រៅប្រទេសនេះ គឺក្រោម ២៥% ប្រចាំឆ្នាំ។ រដ្ឋខិតខំបង្កើនថាមពលក្នុងស្រុក ចំពោះថាមពលពីខាងក្រៅគ្រាន់តែជាថាមពលបំពេញបន្ថែម ពោលគឺឆ្អឹងខ្នងធំនៅតែជាផលិតផលក្នុងស្រុក។ ការនាំចូលអគ្គិសនីពីខាងក្រៅនេះ គឺទី១ បំពេញបន្ថែមការខ្វះខាត និងទី២ បន្ថយការប៉ះពាល់បរិស្ថាន។ បើសិនជាយើងធ្វើទាំងអស់ យើងត្រូវទៅបិទទន្លេ បិទភ្នំ ការបិទទន្លេបិទភ្នំ លុះត្រាតែចាំបាច់ដែលមានប្រយោជន៍ខ្លាំងដល់ជាតិទើបរដ្ឋធ្វើ បើមិនចាំបាច់ខ្លាំងទេ យើងយកពីគេមកតិចតួច ដើម្បីបំពេញបន្ថែម ជៀសវាងការធ្វើឱ្យប៉ះពាល់បរិស្ថាន ធ្វើដូចនេះគឺចំណេញជាង។ ទោះជាប្រទេសជិតខាងលក់អគ្គិសនីឱ្យកម្ពុជា ប្រទេសទាំងនោះ ក៏ទិញភ្លើងពីប្រទេសជិតខាងគេដែរ ដូចជា វៀតណាមទិញភ្លើងពីឡាវ ចិន បន្ថែម។ ចំណែកថៃក៏ទិញភ្លើងពី

ឡាវ និងភូមាជាដើម។ រីឯឡាវ ទិញភ្លើងអគ្គិសនីពីថៃផងដែរ។ ចរន្តនៃការដោះដូរថាមពលនេះ គឺដើម្បីចំណេញទៅចំណេញមក។ នៅឆ្នាំ ២០២២ អគ្គិសនីកម្ពុជា បានត្រៀមថាមពលស្អាតចំនួន ២ប្រភពបន្ថែមទៀត ពោលគឺ ២០មេកាវ៉ាត់ ប្រើដោយពន្លឺព្រះអាទិត្យនៅក្រុងបាវិត ខេត្តស្វាយរៀង ដោយបានដាក់ឱ្យដំណើរការបណ្ដាញជាតិរួចហើយ។ ចំណែកនៅខេត្តកំពង់ឆ្នាំងមាន ៦០មេកាវ៉ាត់ កំពុងរៀបចំសាងសង់ និងត្រៀមយកភ្លើង ១៥០មេកាវ៉ាត់បន្ថែម ពីវារីអគ្គិសនីប្រទេសឡាវ ដើម្បីធ្វើឱ្យថាមពលស្អាតចូលកម្ពុជាបន្ថែមទៀត។ នេះបើតាមលោក កែវ រតនៈ។ លើសពីនេះទៀត ថាមពលក្នុងស្រុកចំនួន ៣៥០មេកាវ៉ាត់ នៅខេត្តព្រះសីហនុដើរដោយធ្យូងថ្ម នឹងត្រូវចេញនៅឆ្នាំ ២០២២ ដែលគម្រោងនេះសាងសងរយៈពេល ៤ឆ្នាំមកហើយ។ បច្ចុប្បន្នថាមពលក្នុងបណ្ដាញជាតិ មិនខ្វះសម្រាប់ដំណើរការសេដ្ឋកិច្ចនិងសង្គមកម្ពុជាទេ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖Kampucheathmeyចេញផ្សាយថ្ងៃទី១១ខែកុម្ភៈឆ្នាំ២០២២។*

## យន្តការដេញថ្លៃនាំចូលជ្រូករស់ផ្គត់ផ្គង់មកកម្ពុជា បំណងការពារចិញ្ចឹមក្នុងស្រុក និងអ្នកហូបសាច់ជ្រូក



ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២២នេះ បានចេញសេចក្ដីប្រកាសព័ត៌មាន ដោយពន្យល់អំពី យន្តការដេញថ្លៃនាំចូលជ្រូករស់ផ្គត់ផ្គង់មកកម្ពុជា ត្រូវបានរៀបចំឡើង ក្នុងគោលបំណងការពារទាំងអ្នកចិញ្ចឹម និងអ្នកហូបសាច់ជ្រូក។ យន្តការដេញថ្លៃនេះ នឹងត្រូវបានយកមកអនុវត្ត ក្នុងករណីដែលមានការខ្វះជ្រូក។

រាជរដ្ឋាភិបាល តែងតែលើកទឹកចិត្តអ្នកចិញ្ចឹមក្នុងស្រុកឱ្យមានលទ្ធភាពផ្គត់ផ្គង់ជ្រូកឱ្យបានគ្រប់គ្រាន់ ជាមួយនឹងកម្រិតថ្លៃសមរម្យ ដោយមិនចាំបាច់មានការនាំចូល។ ក្នុងករណីចាំបាច់ មានតម្រូវការនាំចូលដើម្បីបំពេញសេចក្ដីត្រូវការក្នុងស្រុក ក៏ដូចជារក្សាថ្លៃសាច់ជ្រូកឱ្យស្ថិតនៅក្នុងកម្រិតមួយសមរម្យ យន្តការនេះនឹងពឹងផ្អែកលើក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាស្ថាប័នក្នុងការ (១)៖ កំណត់កូតានៃបរិមាណនាំចូល, (២)៖ កំណត់គុណវុឌ្ឍិនៃក្រុមហ៊ុននាំចូល, និង (៣)៖ ធ្វើការដេញថ្លៃដោយតម្លាភាព។

ការរៀបចំយន្តការដេញថ្លៃនេះ គឺដើម្បីទាក់ទាញក្រុមហ៊ុនចូលរួមឱ្យបានច្រើន ក្នុងការដេញថ្លៃការនាំចូលជ្រូករស់ សំដៅបង្កើនការប្រកួតប្រជែង និងធានាការផ្គត់ផ្គង់ជ្រូករស់ក្នុងកម្រិតថ្លៃមួយសមរម្យ។ការណ៍នេះនឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការធានានិរន្តរភាពនៃការចិញ្ចឹមជ្រូករបស់កសិករ ព្រមទាំងរក្សាឱ្យបាននូវស្ថិរភាពថ្លៃជ្រូករស់ និងថ្លៃសាច់នៅលើទីផ្សារក្នុងកម្រិតមួយសមរម្យ សំដៅជួយទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ក្នុងបរិបទនៃប្រក្រតីភាពថ្មីក្នុងការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ ។

ដើម្បីចូលរួមជំរុញការចិញ្ចឹមជ្រូក ក្នុងស្រុកសំដៅកាត់បន្ថយការនាំចូល និងលើកកម្ពស់ជីវភាពរស់នៅ របស់បងប្អូនអ្នកចិញ្ចឹមសត្វ នាពេលកន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ជាបន្ទុករបស់រដ្ឋនូវអាករតម្លៃបន្ថែមលើជ្រូករស់ និងបានផ្ដល់ឥណទានក្នុងអត្រាការប្រាក់ទាប តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ទៅវិស័យកសិកម្ម រាប់បញ្ចូលទាំងអនុវិស័យចិញ្ចឹមជ្រូកផងដែរ។ បន្ថែមពីនេះ, ដើម្បីបង្កើនភាព

ប្រកួតប្រជែងនៃអនុវិស័យចិញ្ចឹមជ្រូកក្នុងរយៈពេលមធ្យម និងវែង, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានសហការជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការសិក្សាអំពីការវិភាគថ្លៃដើមផលិតកម្មនៃការចិញ្ចឹមជ្រូក និងកំពុងរៀបចំវិធានការដាក់លាក់ពាក់ព័ន្ធនឹងថ្លៃអគ្គិសនី ចំណីពូជ ជីវសុវត្ថិភាព ជាដើម ដើម្បីកាត់បន្ថយថ្លៃដើមនៃការចិញ្ចឹម៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២។*

## រដ្ឋាភិបាលផ្តើមសាកល្បងអនុវត្តកម្មវិធីធានារ៉ាប់រងដំណាំស្រូវដល់កសិករ ប៉ះពាល់ដោយភ្លៀង ឬជំនន់



*ដោយ kampucheathmey*

អភិបាលខេត្តកំពង់ធំ បានមានប្រសាសន៍ថា ដោយមើលឃើញកសិករមួយចំនួនតែងតែទទួលរងនូវផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុលើដំណាំស្រូវ ទើបរាជរដ្ឋាភិបាល បានដាក់ឱ្យដំណើរការសាកល្បងការធានារ៉ាប់រងដំណាំស្រូវដោយផ្អែកលើសន្ទស្សន៍អាកាសធាតុ ក្នុងគោលបំណងឱ្យកសិករអាចទទួលបានសំណងខ្លះ លើការខូចខាតដំណាំស្រូវក្នុងរដូវវស្សា ដែលបណ្តាលមកពីកង្វះទឹកភ្លៀង ឬជំនន់ទឹកភ្លៀង។ កម្មវិធីនេះគឺ កសិករទិញធានារ៉ាប់រងដំណាំស្រូវចំនួន ១០ ដុល្លារ ក្នុង ១ ហិកតា ហើយក្នុងករណីដែលមានការខូចខាតដំណាំស្រូវដោយសារកង្វះទឹកភ្លៀង ឬជំនន់ទឹកភ្លៀងនោះ ក្រុមហ៊ុន Forte នឹងផ្តល់សំណងជូនកសិករដោយស្វ័យប្រវត្តិ ដែលសំណងខ្ពស់បំផុតក្នុងមួយប័ណ្ណធានារ៉ាប់រង គឺ ១០០ ដុល្លារ ឬអាចតិចជាង ១០០ ដុល្លារ ដោយអាស្រ័យលើភាពជាក់ស្តែង នៃបរិមាណទឹកភ្លៀង។

ប្រធានគ្រប់គ្រងកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ បានមានប្រសាសន៍ថា កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ត្រូវបានបង្កើតឡើងដើម្បីចូលរួមអនុវត្តគោលនយោបាយស្រូវអង្ករ របស់រាជរដ្ឋាភិបាល និងមានគោលបំណងបង្កើនចំណូលរបស់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងខ្សែសង្វាក់ផលិតកម្មស្រូវ និងការនាំចេញអង្ករ តាមរយៈការបង្កើនផលិតកម្មស្រូវអង្ករដែលមានគុណភាពខ្ពស់ជាមួយនឹងការគិតគូរអភិរក្សមូលដ្ឋានធនធានធម្មជាតិ ឱ្យនៅគង់វង្សយូរអង្វែង។ កម្មវិធីនេះ កំពុងអនុវត្តលើខេត្តចំនួនបី លើឃុំគោលដៅចំនួន ៩០ ឃុំ ហើយចំពោះខេត្តកំពង់ធំ គឺយើងអនុវត្តចំនួន ៣០ ឃុំ ដោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្មស្រូវ និងអង្ករ មានដូចជា ការកសាងប្រឡាយទឹក ការកសាងឡសម្ងួត និងឃ្លាំងស្តុកស្រូវ ការកសាងមជ្ឈមណ្ឌលពូជស្រូវ ជាដើម។ លោកបានសំណូមពរដល់អ្នកដែលចូលរួមស្វែងយល់ឱ្យបានច្បាស់លាស់ អំពីផលិតផលធានារ៉ាប់រងដំណាំស្រូវផ្អែកលើសន្ទស្សន៍អាកាសធាតុនេះ ដែលជាគំនិតផ្តួចផ្តើមរបស់ រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរួមចំណែកធានាប្រាក់ចំណូលរបស់ប្រជាកសិករក្នុងបរិបទ នៃបម្រែបម្រួលអាកាសធាតុកាន់តែខ្លាំងឡើងៗ ពីមួយឆ្នាំទៅមួយឆ្នាំ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖kampucheathmeyចេញផ្សាយថ្ងៃទី១៣ខែកុម្ភៈឆ្នាំ២០២២។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ការប្រៀបធៀបចំនួនប្រព័ន្ធធនាគារកម្ពុជា នៃ ឆ្នាំ២០២១ *(គិតជាចំនួនគ្រឹះស្ថាន, ឆ្នាំ២០២០-២០២១*

| ប្រព័ន្ធធនាគារ កម្ពុជា ( គិតជាចំនួនគ្រឹះ ស្ថាន ) | ២០២០ | ២០២១ | កំណើន |
|---|---|---|---|
| ធនាគារពាណិជ្ជ | 52 | 54 | 3.8% |
| ធនាគារឯកទេស | 13 | 10 | -23.1% |
| ការិយាល័យតំណាង | 6 | 6 | 0.0% |
| គ្រឹះស្ថានមិក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | 6 | 6 | 0.0% |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ | 75 | 79 | 5.3% |
| ក្រុមហ៊ុនភតិសន្យា | 15 | 17 | 13.3% |
| គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | 24 | 28 | 16.7% |
| គ្រឹះស្ថានឥណទានជនបទ | 245 | 234 | -4.5% |
| អាជីវកម្មប្តូរប្រាក់ | 2882 | 2447 | -15.1% |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

តារាងទី១ ខាងលើនេះបានបង្ហាញ ពីការប្រៀបធៀបចំនួនប្រព័ន្ធធនាគារនៅកម្ពុជា នៃឆ្នាំ២០២១។ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បានកើនឡើង៤ ឬ ស្មើនឹង១៧% (ដល់២៨), ក្រុមហ៊ុនភតិសន្យាកើន២ ឬស្មើនឹង១៣%(ដល់១៧), គ្រឹស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើកើន៤ ឬស្មើនឹង៥%(ដល់៧៩) និងធនាគារពាណិជ្ជកើន២ ឬស្មើជិត៤% (ដល់៥៤) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ការិយាល័យតំណាង និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គឺពុំមានកំណើនទេ ដែលមានចំនួន ៦ ដូចគ្នា។ ប៉ុន្តែធនាគារឯកទេសបានថយចុះ ៣ ឬស្មើនឹង-២៣%(ដល់១០), អាជីវកម្មប្តូរប្រាក់ថយចុះ ១១ ឬស្មើនឹង-៥% (ដល់២៣៤) និងអាជីវកម្មប្តូរប្រាក់ថយចុះ ២៣៥ ឬស្មើនឹង-១៥% (ដល់២៤៤៧) បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២020៕

*ដោយ ឈន ហាំ*

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា ចុះនាថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ប្រធានសភាកូរ៉េខាងត្បូង សន្យាពន្លឿននីតិវិធី ផ្តល់សច្ចាប័នកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ



*ដោយ freshnews*

កម្ពុជា និងកូរ៉េខាងត្បូង កាលពីឆ្នាំ២០២១ កន្លងទៅនេះ បានសម្រេចចុះកិច្ចព្រមព្រៀងធ្វើពាណិជ្ជកម្មសេរីជាមួយគ្នា។ បច្ចុប្បន្នភាគីកម្ពុជា បានរៀបចំរួចរាល់ហើយនូវសេចក្តីព្រាងច្បាប់នៃការធ្វើពាណិជ្ជកម្មសេរីនេះ ដោយភាគីកូរ៉េខាងត្បូង កិច្ចព្រមព្រៀងនេះ កំពុងស្ថិតនៅលើដៃសភាជាតិនៅឡើយ។ គេត្រូវរង់ចាំការអនុម័តឱ្យប្រើប្រាស់នូវច្បាប់នេះសិន ទើបការធ្វើពាណិជ្ជកម្មសេរីរវាងកម្ពុជា និងកូរ៉េខាងត្បូង អាចដំណើរការទៅបាន។

ក្នុងដំណើរទស្សនកិច្ចនៅប្រទេសកូរ៉េខាងត្បូងនាថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២២នេះ សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា បានស្នើទៅកាន់ប្រធានាធិបតីកូរ៉េខាងត្បូង និងប្រធានសភាកូរ៉េខាងត្បូង ឱ្យពន្លឿននូវនីតិវិធីទាំងឡាយ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះបានចូលជាធរមាន ហើយបើកផ្លូវដល់ការធ្វើពាណិជ្ជកម្មសេរីជាមួយកម្ពុជា។ សម្តេច ចង់ឃើញកិច្ចព្រមព្រៀងនេះអាចចូលជាធរមាននៅក្នុងឆ្នាំ២០២២ ដើម្បីជាការអបអរសាទរខួប២៥ឆ្នាំ នៅការបង្កើតទំនាក់ទំនងរវាងកម្ពុជា និងកូរ៉េខាងត្បូង។ កិច្ចព្រមព្រាងពាណិជ្ជកម្មសេរី

នេះ នឹងធ្វើឱ្យបានកាន់តែប្រសើរឡើងនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

ប្រធានសភាកូរ៉េខាងត្បូង បានជម្រាបសម្តេចតេជោនាយករដ្ឋមន្ត្រីថា លោកបានយកការងារនេះមកធ្វើដោយផ្ទាល់ដៃ ហើយនឹងប្រឹងប្រែងជំរុញយ៉ាងណា ឱ្យការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឱ្យចប់សព្វគ្រប់យ៉ាងយូរបំផុត ត្រឹមពាក់កណ្តាលឆ្នាំ២០២២នេះ។ កិច្ចព្រមព្រាងពាណិជ្ជកម្មសេរីកម្ពុជា និងកូរ៉េខាងត្បូង នឹងជាចលករមួយបន្ថែមទៀតក្នុងការរុញកំណើនពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ បន្ថែមពីលើភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ RCEP។

ប្រធានសភាជាតិរបស់កូរ៉េខាងត្បូង ក៏បានកោតសរសើរចំពោះច្បាប់វិនិយោគថ្មីរបស់កម្ពុជា ដែលនឹងរួមចំណែកទាក់ទងការវិនិយោគពីកូរ៉េខាងត្បូង ហើយរូបលោកផ្ទាល់ក៏នឹងជួយជំរុញអ្នកវិនិយោគមកកាន់កម្ពុជាផងដែរ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២។*

## ពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្តាលខែដំបូង នៃខែធ្នូ ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិគយប្រទេសវៀតណាមបានបង្ហាញថា ការនាំចេញសរុបរបស់ប្រទេសវៀតណាម មានចំនួន ១៥,៧៨ ពាន់លានដុល្លារ ខណៈការនាំចូលមានចំនួន ១៥,៥៣ ពាន់លានដុល្លារ។ ដូច្នេះ ប្រទេសវៀតណាមមានអតិរេកពាណិជ្ជកម្មចំនួន ០,២៥ ពាន់លានដុល្លារ សម្រាប់រយៈពេលពាក់កណ្តាលខែដំបូង នៃខែធ្នូ ឆ្នាំ២០២១។

បើធៀបទៅនឹងពាក់កណ្តាលខែចុងក្រោយ នៃខែវិច្ឆិកា ឆ្នាំ២០២១ ការនាំចេញរបស់វៀតណាមបានធ្លាក់ចុះ ៨,៣% នៅក្នុងរយៈពេលពាក់កណ្តាលខែដំបូង នៃខែធ្នូ ឆ្នាំ២០២១។ ការថយចុះនៃនាំចេញរួមចំណែកដោយទូរស័ព្ទ ទូរស័ព្ទដៃ និងគ្រឿងបន្លាស់របស់វាបានថយចុះ ១៤,៨% ស្មើនឹង ៤៤៥ លានដុល្លារ ម៉ាស៊ីន ឧបករណ៍ និងគ្រឿងបរិក្ខារបានថយចុះ ១៦,៤% ស្មើនឹង ៣៦៧ លានដុល្លារ ដែក និងដែកថែបបានថយចុះ ២៦% ស្មើនឹង ១៥២ លានដុល្លារ និងផលិតផលអគ្គិសនីកុំព្យូទ័រ និងគ្រឿងបន្លាស់របស់វាបានថយចុះ ៤,៤% ស្មើនឹង ១១៦ លានដុល្លារ។

ដោយឡែក ការនាំចូលមានទំហំ ១៥,៥៣ ពាន់លានដុល្លារ សម្រាប់រយៈពេលពាក់កណ្តាលខែដំបូង នៃខែធ្នូ ឆ្នាំ២០២១ ដែលមានទំហំដូចគ្នាទៅនឹងពាក់កណ្តាលខែចុងក្រោយ នៃខែវិច្ឆិកា ឆ្នាំ២០២១។ ការនាំចូលប្រេងឆៅបានកើន ៩៩,៥% ស្មើនឹង ១៦០ លានដុល្លារ សារៈធាតុគីមីបានកើន ២៥,៥% ស្មើនឹង ៨៣ លានដុល្លារ។ ស្របពេលដែលការនាំចូលផលិតផលអគ្គិសនីកុំព្យូទ័របានធ្លាក់ចុះ ៤,៨% ស្មើនឹង ១៩១ លានដុល្លារ ពោតបានធ្លាក់ចុះ ៦៥,៤% ស្មើនឹង ១១១ លានដុល្លារ បើធៀបទៅនឹងពាក់កណ្តាលខែចុងក្រោយ នៃខែវិច្ឆិកា ឆ្នាំ២០២១៕*ដោយ ជឹម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១៥,៧៨ |
| ការនាំចេញ | ១៥,៥៣ |
| អតិរេកពាណិជ្ជកម្ម | ០,២៥ |

*ប្រភព៖ Vietnam Customs*

## ពាណិជ្ជកម្មរបស់ប្រទេសម៉ាឡេស៊ី នៅក្នុងខែធ្នូ ឆ្នាំ២០២១

ការនាំចេញរបស់ម៉ាឡេស៊ីមានតម្លៃ ១២៣,៨ ពាន់លានរីងហ្គីត នៅក្នុងខែធ្នូ ឆ្នាំ២០២១ ពោលគឺកើនឡើង ២៩,២% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ ការកើនឡើងនេះ ត្រូវបានជំរុញដោយការនាំចេញក្នុងស្រុក (domestic exports) និងការនាំ

ចេញឡើងវិញ (re-exports)។ ការនាំចេញក្នុងស្រុក មានចំនួន ១០២,៧ ពាន់លានរីងហ្គីត ស្មើនឹង ៨៣% នៃការនាំចេញសរុប។ ដូចគ្នាដែរ ការនាំចេញឡើងវិញ មានតម្លៃ ២១,១ ពាន់លានរីងហ្គីត កើនឡើង ២២,៣% បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ រីឯ ការនាំចូលរបស់ប្រទេសម៉ាឡេស៊ី មានចំនួនសរុប ៩២,៩ ពាន់លានរីងហ្គីត ដែលមានកំណើន ២៣,៦% ឬស្មើនឹង ១៧,៧ ពាន់លានរីងហ្គីត នៅក្នុងខែធ្នូ ឆ្នាំ ២០២១ ។

ដូច្នេះ ប្រទេសម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្មចំនួន ៣០,៩ ពាន់លានរីងហ្គីត ដែលមានកំណើន ៤៩,៥% បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០៕

*ដោយ ជឹម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១២៣,៨ |
| ការនាំចេញ | ៩២,៩ |
| តុល្យភាពពាណិជ្ជកម្ម | ៣០,៩ |

*ប្រភព៖ https://www.dosm.gov*

## ក្រុមមូលនិធិ(IMF)បានព្យាករណ៍លើកំណើនផ.ស.ស របស់ម៉ាឡេស៊ីនឹងបន្តកើនឡើងដល់៥,៧៥% ក្នុងឆ្នាំ២០២២បន្ទាប់ពីអត្រា៣,១%ក្នុងឆ្នាំ២០២១



*ប្រភព៖Thestar, 2022*

យោងតាមការព្យាករណ៍របស់IMFបានបង្ហាញថា៖ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសម៉ាឡេស៊ីបាន ងើបឡើងវិញបន្តិចម្តងៗបន្ទាប់ពីរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យកំណើន ផ.ស.សមាន ត្រឹម៣,១% នៅឆ្នាំ២០២១ នឹងបន្តកើនឡើងដល់ ៥,៧៥% នៅឆ្នាំ២០២២។

កំណើននេះនឹងត្រូវបានគាំទ្រដោយការចេញផ្សាយវ៉ាក់សាំងដ៏គួរឱ្យចាប់អារម្មណ៍របស់អាជ្ញាធរ និងការអនុវត្តយ៉ាងឆាប់រហ័សនៃវិធានការគាំទ្រគោលនយោបាយសេដ្ឋកិច្ច, ការឆ្លើយតបនឹងគោលនយោបាយជំងឺរាតត្បាតដ៏ឆាប់រហ័ស ដែលផ្តោតលើការគាំទ្រដល់គ្រួសារ និងអាជីវកម្មដែលរងផលប៉ះពាល់។ ទន្ទឹមនឹងនេះផង កំណើន ផ.ស.សនៅឆ្នាំ ២០២២ ត្រូវបានជំរុញដោយតម្រូវការក្នុងស្រុកកើនឡើង និងបន្តទទួលបានតម្រូវការខាងក្រៅដ៏រឹងមាំ ។

លើសពីនេះក្រុមការងារIMFបានផ្តល់អនុសាសន៍បន្ថែមលើការគាំទ្រផ្នែកសារពើពន្ធដែលកំណត់គោលដៅរយៈពេលជិតមួយឆ្ពោះទៅរកផ្នែកដែលងាយរងគ្រោះ និងរងគ្រោះខ្លាំងនៃសេដ្ឋកិច្ច និងការវិនិយោគប្រកបដោយផលិតភាព។ គោលនយោបាយសារពើពន្ធគួរតែបន្តមានភាពរហ័សរហួន និងគោលដៅកាន់តែខ្លាំងឡើង ដោយផ្តោតលើការរឹតបន្តឹង ការស្តារឡើងវិញ កាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ច ការការពារផ្នែកដែលងាយរងគ្រោះរបស់ប្រជាជន និងពង្រីកការវិនិយោគប្រកបដោយផលិតភាពស្របតាមអាជ្ញាធរ, ពិនិត្យមើលលើអាទិភាពនៃការចំណាយ។ កត្តាទាំងនេះជាយុទ្ធសាស្រ្តបង្រួបបង្រួមមួយដែលអាចជឿទុកចិត្តបាន ជាក់លាក់ ងាយស្រួល និងមានការប្រាស្រ័យទាក់ទងគ្នាយ៉ាងច្បាស់គួរតែត្រូវបានអនុវត្ត នៅពេលដែលការងើបឡើងវិញត្រូវបានពង្រឹង ដើម្បីបង្កើតសារពើពន្ធឡើងវិញ រក្សានិរន្តរភាពសារពើពន្ធ និងកាត់បន្ថយហានិភ័យសារពើពន្ធ គាំទ្រដោយការអនុវត្តអភិបាលកិច្ចសារពើពន្ធដ៏រឹងមាំ។

ដោយឡែកសម្រាប់ គោលជំហរគោលនយោបាយរូបិយវត្ថុមានលក្ខណៈសមស្រប ហើយវិធានការគាំទ្រផ្នែកហិរញ្ញវត្ថុគួរតែបន្ត និងត្រូវបានកំណត់គោលដៅបន្ថែមទៀត ដើម្បីធានាបាននូវស្ថិរភាព នៅពេលដែលការស្ទុះងើបឡើងវិញកាន់តែរឹងមាំ។ សម្រាប់គោលនយោបាយកំណែទម្រង់រចនាសម្ព័ន្ធដែលបានសម្របសម្រួល និងកំណត់គោលដៅនឹងជួយដោះស្រាយបញ្ហាប្រឈមរចនាសម្ព័ន្ធយូរអង្វែង កំណត់ពីហានិភ័យសេដ្ឋកិច្ច បង្កើនផលិតភាព និងដោះស្រាយវិសមភាព និងបំពេញតាមសេចក្តីប្រាថ្នានៃ ប្រទេសម៉ាឡេស៊ី។*ដោយ សេន ចន្ទី*

*ប្រភព៖thestar.com,ចេញផ្សាយថ្ងៃទី១៤ខែកុម្ភៈ ឆ្នាំ២០២២*

## សេដ្ឋកិច្ចជប៉ុនស្ទុះងើបឡើងវិញដោយសារតម្រូវការបន្តរឹងមាំបើទោះបីមានការរីករាលដាលនៃវីរុសអូមីក្រុង



*ប្រភព៖ businesstimes, 2022*

កំណើនសេដ្ឋកិច្ចនៃប្រទេសជប៉ុនបានស្ទុះងើបឡើងវិញក្នុងរយៈពេលបីខែចុងក្រោយនៃឆ្នាំ ២០២១ដោយសារការធូរស្បើយ នៃករណីឆ្លងមេរោគកូវីដ-១៩ នឹងបានជួយជំរុញការប្រើប្រាស់ឱ្យកើនឡើង ទោះបីជាមានការកើនឡើងនៃថ្លៃដើម និងការកើនឡើងនៃការឆ្លងវីរុសអូមីក្រុងដែលធ្វើឱ្យប៉ះពាល់ដល់ការរំពឹងទុកក៏ដោយ។

តាមរយៈការព្យាករណ៍របស់រដ្ឋាភិបាលជប៉ុនបានបង្ហាញថាៈសេដ្ឋកិច្ចនឹងធ្លាក់ចុះម្តងទៀតក្នុងត្រីមាសទី១នៃឆ្នាំ ២០២២ ដោយសារការកើនឡើងវិញនៃករណី កូវីដ-១៩ និងការរំខាននៃខ្សែសង្វាក់ផ្គត់ផ្គង់ដែលនាំឱ្យប៉ះពាល់ដល់ទិន្នផលរោងចក្រ ដែលបង្កើនបញ្ហាប្រឈមសម្រាប់អ្នកបង្កើតគោលនយោបាយក្នុងការរក្សាការងើបឡើងវិញដ៏ផុយស្រួយនេះ។

សេដ្ឋកិច្ចធំទីបីរបស់ពិភពលោកបានពង្រីកអត្រាកំណើនប្រចាំឆ្នាំដល់ ៥,៤%នៅក្នុងខែតុលាដល់ខែធ្នូ បន្ទាប់ពីបានចុះកិច្ចសន្យាកែប្រែ ២,៧% នៅក្នុងត្រីមាសមុន ដោយបានធ្លាក់ចុះតិចជាងការព្យាករណ៍ទីផ្សារសម្រាប់ការកើនឡើងជាមធ្យមមាន ៥,៨%។

ការកើនឡើងនេះត្រូវបានជំរុញដោយភាគច្រើនគឺការកើនឡើង ២,៧% នៃការប្រើប្រាស់ឯកជន ដែលស្មើនឹងជាងពាក់កណ្តាលនៃ ផ.ស.ស របស់ប្រទេសជប៉ុន ហើយការពង្រីកនេះធៀបនឹងការព្យាករណ៍ទីផ្សារគឺកើនឡើង ២,២%។ ការចំណាយមូលធនបានកើនឡើង ០,៤% ធៀបនឹងការព្យាករណ៍ទីផ្សារ កើនឡើង ០,៥%។ តម្រូវការខាងក្រៅបានបន្ថែម ០,២ពិន្ទុគោល ដល់កំណើន ផ.ស.ស ក្នុងខែតុលាដល់ខែធ្នូ ធៀបនឹងការព្យាករណ៍ទីផ្សារនៃការរួមចំណែក ០,៣ ពិន្ទុគោល។ ប្រទេសជប៉ុនបានបញ្ចប់ការហាមឃាត់នានា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតពីខែតុលាឆ្នាំមុន ដែលរួមជាមួយនឹងការថយចុះនៃករណីកូវីដ-១៩ ព្រមទាំងបានជួយបង្កើនការប្រើប្រាស់រហូតដល់ចុងឆ្នាំ ២០២១។

ដោយឡែកថ្មីៗនេះមានការកើនឡើងនៃករណី អូមីក្រុងបានបង្ខំឱ្យរដ្ឋាភិបាលដាក់ការទប់ស្កាត់ លើតំបន់ភាគច្រើន និងរក្សាការបិទច្រកព្រំដែនមួយចំនួន ដែលទំនងជាកាត់បន្ថយការប្រើប្រាស់ចាប់តាំងពីដើមឆ្នាំនេះ។ ការកើនឡើងនៃការឆ្លងមេរោគ អូមីក្រុងក៏បានបង្ខំឱ្យក្រុមហ៊ុនផលិតមួយចំនួនបញ្ឈប់ការផលិត ដែលបណ្តាលឱ្យមានការរំខានដល់ទិន្នផល និងការពន្យារពេលដឹកជញ្ជូននៅក្រុមហ៊ុនរថយន្តយក្សដូចជា Toyota Motor ជាដើម។

អ្នកសេដ្ឋកិច្ចមួយចំនួនបានធ្វើរំពឹងថា សេដ្ឋកិច្ចជប៉ុននឹងធ្លាក់ចុះនៅត្រីមាសទី១នៃឆ្នាំនេះ ដោយសារកង្វះខាត

បន្ទះឈើប ការផ្គត់ផ្គង់ និងការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចរបស់ចិន ធ្វើឱ្យមានទម្ងន់លើទិន្នផល ដែលបន្ថែមទៅលើភាពទន់ខ្សោយដែលរំពឹងទុកក្នុងការប្រើប្រាស់៕

*ដោយ សេន ចន្ទី*

*ប្រភព៖businesstimes,ចេញផ្សាយថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០២២*

## កម្ពុជា-ថៃ គ្រោងសាងសង់ច្រកព្រំដែនអន្តរជាតិថ្មីៗ



*ដោយ ខេមបូឌាមីស*

ក្រសួងសាធារណការ និងដឹកជញ្ជូន កំពុងពិនិត្យលើគម្រោងសាងសង់ច្រកព្រំដែនអន្តរជាតិថ្មីមួយទៀតជាមួយនឹងប្រទេសថៃ គឺច្រកព្រំដែនថ្មដា ប៉ុន្តែមិនទាន់បញ្ជាក់នៅឡើយទេថា នឹងចាប់ផ្ដើមសាងសង់នៅពេលណា។

ច្រកព្រំដែនអន្តរជាតិថ្មដារ គឺជាច្រកព្រំដែនអន្តរជាតិដ៏សំខាន់មួយ ដើម្បីជំរុញទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពី និងបង្កើនឱកាសវិនិយោគផងដែរ។ បច្ចុប្បន្នកម្ពុជាមានច្រកព្រំដែនអន្តរជាតិដោះដូរពាណិជ្ជកម្មទំនិញជាមួយថៃតែមួយប៉ុណ្ណោះ ក្រៅពីនោះ គឺជាច្រកព្រំដែនតាមតំបន់ប៉ុណ្ណោះ។

អ្នកនាំពាក្យក្រសួងសាធារណៈការ និងដឹកជញ្ជូន បានលើកឡើងថា ប្រទេសកម្ពុជា និងប្រទេសថៃ មិនមានតែច្រកព្រំដែនអន្តរជាតិតែមួយនោះទេ ប៉ុន្តែ ច្រកព្រំដែនអន្តរជាតិដែលអនុញ្ញាតឱ្យមានការចរាចរណ៍ចេញ-ចូលទំនិញ គឺមានតែមួយប៉ុណ្ណោះ។ ប្រទេសថៃមានភាពខុសប្លែកពីប្រទេសក្បែរខាងកម្ពុជាផ្សេងទៀតដូចជា វៀតណាម និងឡាវ ដែលភាគច្រើនមានការដោះដូរទំនិញតាមច្រកព្រំដែនតាមតំបន់ជាងតាមច្រកអន្តរជាតិ។ ក្រៅតែពីច្រកព្រំដែនរវាងកម្ពុជា និងថៃ បច្ចុប្បន្នកម្ពុជាក៏មានការដោះដូរទំនិញយ៉ាងមមាញឹកនៅតាមច្រកព្រំដែនរវាងវៀតណាម និងឡាវផងដែរ។ ក្នុងនោះ កម្ពុជា និងប្រទេសវៀតណាម មានច្រកព្រំដែនសរុបរហូត១៦ ឯណោះ។ ទំហំពាណិជ្ជកម្មរវាងកម្ពុជា-ថៃ សម្រេចបានទឹកប្រាក់ប្រមាណ៨ពាន់បីលានដុល្លារ នៅឆ្នាំ២០២១ ដែលមានការកើនឡើង ១០% បើប្រៀបនឹងឆ្នាំ២០២០។ ក្នុងនោះ ការនាំចេញរបស់កម្ពុជា ទៅប្រទេសថៃ បានធ្លាក់ចុះចំនួន២២% ខណៈការនាំចូលពីថៃវិញ មានការកើនឡើង១៦%៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២។*

## ក្រុមហ៊ុនអាមេរិកស្នើអាជ្ញាធរឱ្យយកពន្ធនាំចូលបន្ទះសូឡាពីប្រទេសតំបន់អាស៊ីអាគ្នេយ៍ចំនួន៤រួមទាំងកម្ពុជា



*ដោយ ខេមបូឌាមីស*

ក្រុមហ៊ុនដំឡើងបន្ទះសូឡា Auxin ដែលមានមូលដ្ឋាននៅរដ្ឋកាលីហ្វ័រញ៉ាសហរដ្ឋអាមេរិក បានដាក់ញត្តិថ្មីមួយទៅកាន់ក្រសួងពាណិជ្ជកម្មអាមេរិកកាលពីថ្ងៃទី ៨ កុម្ភៈ នេះ ដោយស្នើសុំឱ្យមានការពិនិត្យឡើងវិញលើការនាំចូលបន្ទះសូឡាពីប្រទេសកម្ពុជា ម៉ាឡេស៊ី ថៃ និងវៀតណាម។ ការដាក់ញត្តិនេះធ្វើឡើងប៉ុន្មានថ្ងៃបន្ទាប់ពីរដ្ឋបាលរបស់ប្រធានាធិបតីអាមេរិកលោក ចូបៃដិន បានបន្តការយកពន្ធគយ ប៉ុន្តែក៏បានបន្ធូរបន្ថយពន្ធលើផលិតផលថាមពលពន្លឺព្រះអាទិត្យដែលផលិត

នៅបរទេស ដែលប្រការនេះបានធ្វើឱ្យក្រុមហ៊ុនផលិតបន្ទះសូឡាតូចៗនៅអាមេរិកខកចិត្ត។ អ្នកផលិតបន្ទះសូឡាក្នុងស្រុករបស់អាមេរិកបានស្វែងរកដំណោះស្រាយម្តងហើយម្តងទៀតជុំវិញការនាំចូលបន្ទះសូឡានេះ ដោយពួកគេបាននិយាយថា ផលិតផលរបស់ពួកគេមិនអាចប្រកួតប្រជែងជាមួយនឹងបន្ទះសូឡាផលិតនៅអាស៊ីដែលមានតំលៃថោក បាននោះទេ។
ប៉ុន្តែក្រុមហ៊ុនពាណិជ្ជកម្មបន្ទះសូឡាធំៗរបស់សហរដ្ឋអាមេរិកវិញ បានប្រឆាំងនឹងរនាំងពន្ធគយនេះ ដោយសារតែសមាជិករបស់ពួកគេ ដែលមានដូចជាអ្នកអភិវឌ្ឍន៍ឧបករណ៍ និងការដំឡើងបន្ទះសូឡា ពឹងផ្អែកលើការនាំចូលផលិតផលតម្លៃថោក ដើម្បីប្រកួតប្រជែងជាមួយឥន្ធនៈហ្វូស៊ីល។
គួររំឭកថា ប្រធានាធិបតីអាមេរិក Joe Biden កាលពីថ្ងៃសុក្រសប្តាហ៍មុន បានចុះហត្ថលេខាបន្តការយកពន្ធលើបន្ទះសូឡានាំចូលពីក្រៅប្រទេស ដែលចាប់អនុវត្តតាំងពីជំនាន់លោក ដូណាល់ ត្រាំ នៅជាប្រធានាធិបតីម្ល៉េះ ពិសេសបន្ទះសូឡានាំចូលពីប្រទេសចិនទាំងអស់តែម្តង។ គេនៅចាំបានថា កាលពីរដ្ឋបាលលោក Donald Trump ពោលគឺនៅឆ្នាំ២០១៨អាមេរិកបានផ្តើមបន្ថែមពន្ធលើការនាំចូលផលិផលបន្ទះសូឡាពីប្រទេសចិន ក្នុងអត្រា ៣០% ហើយក្រោយមកចុះមកនៅត្រឹម ១៥%វិញ៕ *ដោយ ម៉ែន ខែមរៈ*
*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២។*

## ការកក់ជើងហោះហើរអន្តរជាតិមកកាន់អាស៊ីអាគ្នេយ៍កើនឡើង


*ដោយ ខេមបូណ្ឌមីស*

ការកក់ជើងហោះហើរអន្តរជាតិមកកាន់បណ្តាប្រទេសអាស៊ីអាគ្នេយ៍ កំពុងមានការកើនឡើងគួរឱ្យកត់សម្គាល់ក្រោយពីមានការបន្ធូរបន្ថយការរឹតបន្តឹងព្រំដែន បើទោះបីជាមានករណីឆ្លងជំងឺរាតត្បាតកូវីដ១៩នៅបន្តកើនឡើងនៅក្នុងខែមករានេះក្តី។ កាលពីឆ្នាំ២០២១ ការធ្វើដំណើររបស់អ្នកដំណើរអន្តរជាតិនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកបានធ្លាក់ចុះ ៩៣% ដោយសារការរាតត្បាតនៃជំងឺកូវីដ១៩ ដែលវាធ្វើឱ្យប៉ះពាល់ខ្លាំងពិសេសអាជីវកម្មអាកាសចរណ៍ ។
ទោះបីជា ប្រទេសមួយចំនួនដូចជាប្រទេសថៃ ហ្វីលីពីន វៀតណាម ឥណ្ឌូនេស៊ី កម្ពុជា និងសិង្ហបុរី ដែលកំពុងមានការកើនឡើងមេរោគបំប្លែងថ្មី អូមីក្រុងក៏ដោយ ប៉ុន្តែ ប្រទេសទាំងនេះនៅតែបើកដំណើរការឡើងវិញ និងទទួលអ្នកដំណើរដែលបានចាក់វ៉ាក់សាំងរួច ក្នុងនោះក៏មានការលើកលែងការធ្វើចត្តាឡីស័កផងដែរ។
ទិន្នន័យពីស្ថាប័នទេសចរណ៍អង់គ្លេស Skyscanner អ្នកធ្វើដំណើរដែលបានកក់សំបុត្រទៅកាន់ប្រទេសតំបន់អាស៊ីអាគ្នេយ៍ភាគច្រើនគឺជាអ្នកមកពី ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងអាល្លឺម៉ង់ ដែលបានកើនឡើងចន្លោះពី ១៩ ទៅ ៣០០%ឯណោះ នៅក្នុងខែមករាកន្លងទៅនេះ។ ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខនេះ គេនឹងឃើញទីផ្សារធ្វើដំណើរសកលលោកនឹង

ចាប់ផ្តើមការងើបឡើងវិញ កាន់តែច្រើនឡើងថែមទៀត។

ប្រទេសអូស្ត្រាលីថ្មីៗនេះ បានប្រកាសនឹងបើកព្រំដែនរបស់ខ្លួនឡើងវិញចំពោះភ្ញៀវទេសចរអន្តរជាតិចាប់ពីថ្ងៃទី ២១ ខែកុម្ភៈ ដែលនាំឱ្យមានការកក់សំបុត្រកើនឡើង ២០០%ឯណោះ នៅថ្ងៃដំបូង។ ស្របពេលជាមួយគ្នានោះដែរ ក្រុមហ៊ុនអាកាសចរណ៍ Qantas Airways កាលពីថ្ងៃពុធបានបញ្ជាក់ដែរថា ខ្លួនបានឃើញពីការកើនឡើងគួរឱ្យកត់សម្គាល់នូវការកក់បំកបុត្រយន្តហោះសម្រាប់ការធ្វើដំណើរអន្តរជាតិ ចាប់តាំងពីពេលដែលប្រទេសអូស្ត្រាលីបានប្រកាសបើកព្រំដែនឡើងវិញ។

បើទោះបីជា ការការធ្វើដំណើរអន្តរជាតិបង្ហាញពីសញ្ញាវិជ្ជមាននៃការស្ទុះងើបឡើងវិញក្តី ប៉ុន្តែ បើមើលទៅលើប្រទេសចិនដែលជាប្រភពភ្ញៀវទេសចរដ៏សំខាន់នោះ គឺនៅតែបន្តវិធានការយ៉ាងតឹងរ៉ឹងលើកូវីដ១៩ ហើយវាក៏កំពុងជះឥទ្ធិពលដល់ការធ្វើដំណើរអន្តរជាតិ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២។*

## កត្តាដែលធ្វើឱ្យការនាំចេញទៅចិនធ្លាក់ចុះជាង១០% នៅដើមខែ ឆ្នាំ២០២២




*ដោយ ខេមបូណ្ឌមីស*

នៅក្នុងខែមករាឆ្នាំ២០២២ ការនាំចេញទំនិញពីកម្ពុជាទៅចិនសម្រេចបានតែជិត ៨២លានដុល្លារអាមេរិក ប៉ុណ្ណោះ ធ្លាក់ចុះជាង១០%បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២១ គឺដោយសារទំនិញកម្ពុជាមួយចំនួន ដែលនាំចេញទៅចិនតាមរយៈច្រកព្រំដែនវៀតណាមត្រូវបានរាំងស្ទះ បន្ទាប់ពីចិនរឹតបន្តឹងការនាំចូលទំនិញពីវៀតណាមក្រោមវិធានការទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩។ ម្យ៉ាងទៀត នៅក្នុងអំឡុងខែមករាមានក្រុមហ៊ុននាំចេញមួយចំនួនម ិនទាន់មានការនាំចេញ និងមួយចំនួនបានផ្អាកការនាំចេញដោយសារប្រទេសចិនប្រារព្ធពិធីបុណ្យចូលឆ្នាំចិនជាដើម។

ចំពោះការនាំចេញកសិផលពីកម្ពុជាទៅចិននៅតែបង្ហាញវិជ្ជមានគួរឱ្យកត់សម្គាល់។ នៅខែមករា ឆ្នាំ២០២២ ការនាំចេញសម្រេចបានជាង ៩៣ម៉ឺនតោនកើនឡើងជិត១៦%បើធៀបនឹងខែមករា កាលពីឆ្នាំ២០២១ ដែលមានត្រឹមជាង៨០ម៉ឺនតោនប៉ុណ្ណោះ។

ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជានៅខែមករា ដើមឆ្នាំ២០២២ ការនាំចេញអង្ករពីកម្ពុជាទៅចិន សម្រេចបានជាង៣ម៉ឺនតោនកើនឡើងជាង៦០%បើធៀបនឹងខែមករា ឆ្នាំ២០២១។ កំណើននេះ គឺដោយសារតម្រូវការអង្ករកម្ពុជានៅចិនមានការកើនឡើង គួបផ្សំនៅកម្ពុជាខែនេះជារដូវប្រមូលផលស្រូវ។ នៅចិនលក់ចេញជាមធ្យម៦០០ដុល្លារអាមេរិកក្នុង១តោន ថោកជាងប្រមាណ១០០ដុល្លារអាមេរិក បើធៀបនឹងទីផ្សារអឺរ៉ុប។ ប៉ុន្តែអង្ករដែលកម្ពុជានាំចេញទៅចិនភាគច្រើនជាប្រភេទអង្ករស ខណៈទៅទីផ្សារអឺរ៉ុបភាគច្រើនជាប្រភេទអង្ករក្រអូប។

ក្រសួងពាណិជ្ជកម្ម បានបញ្ជាក់ថា មកទល់ពេលនេះ មិនទាន់មានការនាំចេញទំនិញពីកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិណា ធ្វើឡើងក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់នោះទេ តាំងពីកិច្ចព្រមព្រៀងទាំងពីរនេះបានចូលជាធរមានជាង១ខែកន្លងមកនេះទេ។ បញ្ហានេះបណ្តាលមកពីអ្នកនាំចេញ

ខ្លះមិនទាន់ចាប់អារម្មណ៍ក្នុងការនាំចេញទៅទីផ្សារថ្មី ឬកំពុងសិក្សាពីផលចំណេញ ទើបពួកគេមិនទាន់ហ៊ាននាំចេញក្រោមកិច្ចព្រមព្រៀងទាំងពីរនេះ។ ម្យ៉ាងទៀតអាចមានអ្នកនាំចេញខ្លះគិតថា ការនាំចេញរបៀបចាស់ និងទៅទីផ្សារចាស់ ល្អប្រសើរហើយជាដើម៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីស ចេញផ្សាយថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២។*

## សេដ្ឋកិច្ចសកល

### រដ្ឋមន្ត្រីក្រសួងថាមពលតំណាងប្រទេសអេហ្ស៊ីប និងស៊ីប បង្ហាញនូវការព្រួយ បារម្ភអំពីការកើនឡើងតម្លៃប្រេងឆៅលើសពី ១០០ដុល្លារអាមេរិក ក្នុងមួយបារ៉ែល




*ប្រភព៖ CNBC ២០២២*

រដ្ឋមន្ត្រីក្រសួងថាមពលតំណាងឱ្យប្រទេសអេហ្ស៊ីប និងស៊ីប (Cyprus) លោក Tarek El Molla និងលោកស្រី Natasa Pilides បានបង្ហាញនូវក្តីបារម្ភយ៉ាងខ្លាំងអំពីសក្តានុពលនៃការកើនឡើងតម្លៃប្រេងលើសពី ១០០ ដុល្លារអាមេរិក ក្នុងមួយបារ៉ែល អំឡុងពេលសន្និសីទពិព័រណ៍ប្រេង និងឧស្ម័ននៅរដ្ឋធានី Cairo នៃប្រទេសអេហ្ស៊ីប កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២។ ការព្រួយបារម្ភនេះ កើតឡើងនៅពេលដែលប្រទេសជាងដប់បានជំរុញឱ្យពលរដ្ឋរបស់ពួកគេចាកចេញពីប្រទេសអ៊ុយក្រែន ចំពេលមានការព្រមានអំពីការឈ្លានពានរបស់ប្រទេសរុស្ស៊ីដែលជិតមកដល់។

ជាក់ស្តែង តម្លៃប្រេង Brent របស់អង់គ្លេសបានកើនឡើងដល់កម្រិតខ្ពស់ថ្មីក្នុងរយៈពេល ៧ឆ្នាំ ដោយសារការកើនឡើងភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយសកល បើទោះបីជា តម្លៃប្រេងនេះត្រូវបានជួញដូរនៅតម្លៃ ៩៤,៣៣ដុល្លារអាមេរិក ពោលគឺធ្លាក់ចុះ ០,១% បន្ទាប់ពីកើនឡើងដល់កំពូលក្នុងតម្លៃ ៩៦,១៦ដុល្លារអាមេរិក ក្នុងមួយបារ៉ែល ក្តី។ ចំណែកឯ តម្លៃប្រេងឆៅរបស់សហរដ្ឋអាមេរិក (WTI) បានឈរនៅតម្លៃ ៩៣,២ដុល្លារអាមេរិក កើនឡើងប្រហែល ០,១% ក្នុងមួយបារ៉ែល។

ដោយឡែក រដ្ឋមន្ត្រីក្រសួងថាមពលនៃប្រទេសអ៊ីស្រាអែល លោក Karine Elharrar បានមានប្រសាសន៍ថា ប្រសិនបើយើងមិនចង់ឱ្យតម្លៃប្រេងឡើងដល់ ១០០ ដុល្លារអាមេរិក ក្នុងមួយបារ៉ែលទេនោះ យើងត្រូវធ្វើឱ្យប្រាកដថាយើងមានពិពិធកម្មនៃប្រភពថាមពល។ ជុំវិញភាពតានតឹងនេះ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបបានគំរាមដាក់ទណ្ឌកម្មលើប្រទេសរុស្ស៊ី ប្រសិនបើរុស្ស៊ីឈ្លានពានប្រទេសអ៊ុយក្រែន។ បញ្ហានេះ បានបង្កើនការភ័យខ្លាចនៃការរំខានការផ្គត់ផ្គង់ប្រេងដែលអាចកើតមានឡើងពីប្រទេសផលិតប្រេងចម្បងមួយនេះរបស់ពិភពលោក។ ទោះយ៉ាងណា រុស្ស៊ីបានបដិសេធម្តងហើយម្តងទៀតចំពោះផែនការចូលឈ្លានពានអ៊ុយក្រែនដែលមានទាហានប្រហែល ១០ម៉ឺននាក់ នៅព្រំដែនប្រទេសអ៊ុយក្រែន៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ CNBC ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២*

## ការលក់បន្ទះឈីបសកល បំបែកកំណត់ត្រាខ្ពស់បំផុតក្នុងឆ្នាំ២០២១ ខណៈ ការលក់នឹងកើនឡើង ៨,៨% នៅឆ្នាំ២០២២



*ប្រភព៖ CNA ២០២២, រូបភាព៖ REUTERS/Yves Herman*

ការលក់បន្ទះឈីបសកល បានកើនឡើងក្នុងកំណត់ត្រាខ្ពស់បំផុតនៅឆ្នាំ២០២១ ដែលមានតម្លៃជាទឹកប្រាក់ ៥៥៥,៩ប៊ីលានដុល្លារអាមេរិក ពោលគឺកើនឡើង ២៦,២% ខណៈ ការលក់ត្រូវបានព្យាករណ៍ថានឹងមានកំណើន ៨,៨% នៅឆ្នាំ២០២២ នេះ ដោយសារក្រុមហ៊ុនផលិតបន្ទះឈីបបន្តបង្កើនសមត្ថភាពផលិតកម្មដើម្បីបំពេញតាមតម្រូវការ នេះបើយោងតាមលោក John Neuffer នាយកប្រតិបត្តិនៃសមាគមឧស្សាហកម្មផលិតវត្ថុពាក់កណ្តាលចម្លង (SIA)។

លោកបានបន្ថែមថា ការលក់បន្ទះឈីបនៅឆ្នាំ២០២០ បានកើនឡើង៦,៨%ធៀបនឹងឆ្នាំ២០១៩ ខណៈចំនួនការលក់នៅក្នុងឆ្នាំ២០២១ គឺជាឆ្នាំដំបូងចាប់តាំងពីឆ្នាំ ២០១៨ មក ដែលបន្ទះឈីបលក់បានលើសពី ១ទ្រីលានឯកតា។ ប្រទេសចិននៅតែជាទីផ្សារធំសម្រាប់វត្ថុពាក់កណ្តាលចម្លងជាមួយនឹងការលក់សរុប ១៩២,៥ ប៊ីលានដុល្លារក្នុងឆ្នាំ២០២១ កើនឡើង ២៧,១%

លោក Neuffer បានបញ្ជាក់ថាការកើនឡើងនៃនិន្នាការឌីជីថលភាវូបនីយកម្មដោយសារជំងឺរាតត្បាតកូវីដ-១៩ នឹងបន្តជំរុញការកើនឡើងនៃតម្រូវការ ដែលជាហេតុផលរបស់ក្រុមហ៊ុនផលិតគ្រឿងអេឡិចត្រូនិកធំៗដូចជា Taiwan Semiconductor Manufacturing Co, Samsung Electronics Co, និង Intel Corp បានប្រកាសពីការវិនិយោគរាប់សិបពាន់លានដុល្លារអាមេរិកសម្រាប់ការសាងសង់រោងចក្រថ្មីៗកាលពីឆ្នាំ២០២១។

*ដោយ ស៊ិន សុភាព៌*

*ប្រភព៖ CNA ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២*

## តើគោលនយោបាយគ្មានកូវីដ១៩របស់ចិន ពិតជាកំពុងគំរាមកំហែង ដល់កំណើនសេដ្ឋកិច្ចពិភពលោក?



*ដោយ ខេមបុណ្ណមីស(គ្រូពេទ្យ បាញ់ថ្នាំសម្លាប់មេរោគកូវីដ១៩ នៅប្រទេសចិន)*

អ្នកបង្កើតគោលនយោបាយធនាគារកណ្តាលជប៉ុន បាននិយាយថា គោលនយោបាយគ្មានកូវីដ១៩ ឬកូវីដ១៩ស្មើសូន្យរបស់ទីក្រុងប៉េកាំង ទំនងជាបានដាក់សម្ពាធទៅលើកំណើនសេដ្ឋកិច្ចសកល។ ចិនជាប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់ធំ ហើយក៏ជាក្បាលម៉ាស៊ីនដឹកនាំសេដ្ឋកិច្ចពិភពលោក ពិសេសលើផ្នែកទីផ្សារ និងឧស្សាហកម្ម។ ដូច្នេះគោលនយោបាយនេះ នៅក្នុងពេលអូមីក្រុងកំពុងរាតត្បាតស្រាប់ផងនោះ អាចជះឥទ្ធិពលមិនល្អដល់កំណើនសេដ្ឋកិច្ចពិភពលោក ដោយធ្វើឱ្យខ្សែសង្វាក់ផ្គត់ផ្គង់ដែលកំពុងតែយ៉ាប់យឺនស្រាប់ ជួបបញ្ហាកាន់តែខ្លាំង និងធ្វើឱ្យអត្រាអតិផរណាបន្តកើនឡើងខ្ពស់ទៅៗ។

មូលនិធិរូបិយវត្ថុអន្តរជាតិIMF បានព្រមានថា ប្រទេសចិនគួរតែគិតឡើងវិញពីការអនុវត្តគោលនយោបាយ

គ្មានកូវីដ១៩មួយនេះ ដើម្បីបន្ធូរបន្ថយភាពតានតឹងខាងខ្សែសង្វាក់ផ្គត់ផ្គង់។

អ្នកជំនាញផ្នែកជំងឺឆ្លងអាមេរិក បាននិយាយដែរថា អូមីក្រុង មិនដូចជាមេរោគកូវីដ១៩ដទៃទៀតនោះឡើយ។ ការព្យាយាមបញ្ឈប់អូមីក្រុង គឺដូចជា ព្យាយាមបញ្ឈប់ខ្យល់កុំឱ្យបោកបក់ដែរ។

ចិនជាប្រទេសមានសេដ្ឋកិច្ចជឿនលឿនតែមួយគត់ ដែលនៅបន្តប្រកាន់ខ្ជាប់នូវគោលនយោបាយតឹងរ៉ឹងបំផុត ដើម្បីទប់ស្កាត់ជំងឺរាតត្បាតកូវីដ១៩ ប៉ុន្តែនៅតែអាចសម្រេចបានកំណើនសេដ្ឋកិច្ច ៨,១% ឆ្នាំ២០២១ ។ អាជ្ញាធរក្រុងប៉េកាំង នៅតែបន្តជឿជាក់លើគោលនយោបាយរបស់ខ្លួន និងបានអះអាងថា គ្មានវិធីសាស្ត្រអ្វីដែលអាចទប់ស្កាត់កូវីដ១៩មានប្រសិទ្ធិភាព ល្អជាងអ្វីដែលប៉េកាំងបានធ្វើនោះទេ ហើយប្តេជ្ញាអនុវត្តគោលនយោបាយនេះបន្តទៀត៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២។*

## ចិនផ្អាកការនាំចូលសាច់គោពីប្រទេសលីទុយអានី



*ដោយ ខេមបូណ្ឌមីស*

ចិនបានសម្រេចផ្អាកនាំចូលសាច់គោ ទឹកដោះគោ និងស្រាបៀរពីប្រទេសលីទុយអានីចាប់ពីសប្តាហ៍នេះតទៅ។ ការផ្អាកនេះ បានបន្ថែមនូវភាពតានតឹងកាន់តែខ្លាំងថែមទៀត ទៅលើជម្លោះពាណិជ្ជកម្មចិន និងប្រទេសសមាជិកសហភាពអឺរ៉ុបមួយនេះ។

អាជ្ញាធរនៃប្រទេសលីទុយអានី បាននិយាយថាប្រទេសចិនកំពុងបញ្ឈប់ការនាំចេញទំនិញពីលីទុយអានីទៅចិន ដោយសារតែផលិតផលមិនមានឯកសារត្រឹមត្រូវ។ នេះជាការជូនដំណឹងលើកដំបូង ដែលខ្លួនមិនធ្លាប់បានទទួលពីមុនមកនោះទេ ព្រោះរាល់ដងពេលនាំចូលទំនិញទៅចិន ចិនតែងតែសួររកព័ត៌មានខ្វះខាតនោះជាមុនសិន។

រដ្ឋបាលគយចិនបានបញ្ជាក់ថា ខ្លួនបានបញ្ឈប់ការនាំចូលសាច់គោលីទុយអានី ប៉ុន្តែមិនបានផ្តល់ហេតុផលជាក់លាក់ណាមួយឡើយ។

ទំនាក់ទំនងបានបែកបាក់រវាងប្រទេសចិន និង ប្រទេសលីទុយអានី បន្ទាប់ពីប្រទេសលីទុយអានីបានអនុញ្ញាតឱ្យកោះតៃវ៉ាន់បើកការិយាល័យតំណាងនៅក្នុងប្រទេសរបស់ខ្លួន ក្រោមឈ្មោះថា «តៃវ៉ាន់» ជំនួសឱ្យការប្រើឈ្មោះថា«កោះតៃវ៉ាន់នៃប្រទេសចិន»នៅក្នុងរដ្ឋធានី Vilnius របស់ខ្លួនកាលពីឆ្នាំមុន ដោយបានធ្វើឱ្យទីក្រុងប៉េកាំងខឹងសម្បារយ៉ាងខ្លាំង។ ក្នុងនោះប្រទេសចិនបានព្រមានប្រទេសលីទុយអានី តាមរយៈការដាក់សម្ពាធសេដ្ឋកិច្ចពាណិជ្ជកម្មជាច្រើនលើកមកហើយដែរ ហើយក៏បានប្តឹងគ្នានៅអង្គការពាណិជ្ជកម្មពិភពលោកផងដែរ។

ចក្រភពអង់គ្លេសបាននិយាយកាលពីថ្ងៃចន្ទថា ខ្លួននឹងចូលរួមជាមួយសហរដ្ឋអាមេរិក និងអូស្ត្រាលីក្នុងការគាំទ្រពាណិជ្ជកម្មរបស់សហភាពអឺរ៉ុបប្រឆាំងនឹងប្រទេសចិន នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកជុំវិញការហាមឃាត់ពាណិជ្ជកម្មរបស់ទីក្រុងប៉េកាំងលើប្រទេសលីទុយអានី។

គណៈកម្មការអឺរ៉ុបនិយាយថា ការនាំចេញសរុបពីប្រទេសលីទុយអានីទៅកាន់ប្រទេសចិនបានធ្លាក់ចុះ ៩១% នៅក្នុងខែធ្នូឆ្នាំ២០២១ បើធៀបនឹងខែធ្នូឆ្នាំ ២០២០។

ប្រទេសលីទុយអានី បានអះអាងថា ខ្លួនមិនបាននាំចេញផលិតផលអាហារ រួមទាំងសាច់គោទៅប្រទេសចិនតាំងពីដើមខែធ្នូ ឆ្នាំ ២០២១ម្ល៉េះ។

ដោយឡែក អ្នកនាំពាក្យក្រសួងការបរទេសចិនបានបដិសេធមិនបញ្ជាក់លម្អិត អំពីការផ្អាកសាច់គោអូស្ត្រាលីនោះទេ ប៉ុន្តែបាននិយាយថា ប្រទេសលីទុយអានីគួរតែកែតម្រូវ "កំហុស" របស់ខ្លួនឡើងវិញ។

ប្រទេសចិនគឺជាប្រទេសនាំចូលសាច់គោលំដាប់កំពូលរបស់ពិភពលោក ប៉ុន្តែ ការនាំចូលសាច់គោពីប្រទេសលីទុយអានីគឺមានតិចតួចប៉ុណ្ណោះ ពោលគឺមានប្រមាណជិត ៨០០ តោនកាលពីឆ្នាំ ២០២១ ខណៈដែលចិនបាននាំចូលសាច់គោសរុបជាង២លានតោន៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌីសចេញផ្សាយថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២។*

## ក្រុមហ៊ុនផលិតប្រេងធំៗរកបានប្រាក់ចំណេញច្រើន



*ដោយ ខេមបូណ្ឌីស*

ក្រុមហ៊ុនផលិតប្រេងធំៗចំនួន៣ រួមមាន ក្រុមហ៊ុនអាមេរិក ExxonMobil ក្រុមហ៊ុន TotalEnergies របស់បារាំង និងក្រុមហ៊ុនយក្សរបស់ចក្រភពអង់គ្លេស Shell និង BP បានប្រកាសកាលពីសប្តាហ៍មុនថា ប្រាក់ចំណេញក្នុងឆ្នាំ២០២១សរុបមានចំនួនជិត៦៧ពាន់លានដុល្លារអាមេរិក។ ក្នុងនោះ ExxonMobil ចំណេញ ២៣ពាន់លានដុល្លារក្នុងឆ្នាំ២០២១ Shellចំណេញ ២០ពាន់លានដុល្លារ ក្រុមហ៊ុន TotalEnergies ចំណេញ ១៦ពាន់លានដុល្លារ។ កាលពីឆ្នាំ២០២០ ពួកគេបានប្រកាសពីការខាតបង់នៅពេលដែលជំងឺរាតត្បាតបានលេចឡើង ដែលមានការបិទប្រទេស និងជើងហោះហើរ សេដ្ឋកិច្ចពិភពលោកមានការផ្អាកសកម្មភាព និងបណ្តាលឱ្យតម្លៃប្រេងឆៅធ្លាក់ចុះ។ ប៉ុន្តែនៅឆ្នាំ២០២១ តម្លៃប្រេង និងឧស្ម័នបានកើនឡើងយ៉ាងខ្លាំងវិញ ដោយបានឡើងដល់ ជាង៧០ ដុល្លារឯណោះក្នុងមួយបារ៉ែល ខណៈដែលប្រេងឆៅអាមេរិក បានកើនឡើងដល់កម្រិតខ្ពស់បំផុត ពិសេសកាលពីខែមករា ស្របពេលដែលបច្ចុប្បន្នវាមានតម្លៃប្រហែល ៩០ដុល្លារអាមេរិកក្នុងមួយបារ៉ែល។ ទន្ទឹមនឹងនេះ តម្លៃឧស្ម័នក៏បានឡើងដល់កំណត់ត្រាខ្ពស់បំផុតផងដែរនៅតំបន់អឺរ៉ុប។

តម្លៃប្រេងបានឡើងវិញគួរកត់សម្គាល់បន្ទាប់ពីវិបត្តិកូវីដ១៩បានធូរស្បើយ ធ្វើឱ្យក្រុមហ៊ុនផ្តើមមើលឃើញពីប្រាក់ចំណេញ។ ប៉ុន្តែអ្នករងគ្រោះពិតប្រាកដគឺ ពលរដ្ឋសាមញ្ញទូទាំងពិភពលោក ដែលពឹងផ្អែកលើការប្រេងសម្រាប់ជីវភាពប្រចាំថ្ងៃ។ ភាគច្រើននៃពួកគេកំពុងបង្កើនការចំណាយលើថ្លៃឥន្ធនៈ ដែលបន្តកើនឡើងពីមួយខែទៅមួយខែ។ អ្នកជំនាញព្យាករប្រេងឆៅអាចឡើងដល់១០០ដុល្លារក្នុងមួយបារ៉ែលនៅក្នុងឆ្នាំនេះ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌីសចេញផ្សាយថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២។*

## ក្រុមហ៊ុនភេសជ្ជៈ Coca-Cola និង PepsiCo ព្រមានពីការប៉ះពាល់ប្រាក់ចំណេញ ខណៈអតិផរណាកើនឡើង




*ដោយ ខេមបូណ្ឌីស*

ក្រុមហ៊ុន កូកាកូឡា និង PepsiCo កំពុងបារម្ភថាប្រាក់ចំណេញរបស់ខ្លួននៅឆ្នាំ២០២២នេះ អាចនឹងថយចុះដោយសារតែការកើនឡើងនៃអតផិរណា ទៅលើតម្លៃទំនិញ។ ការដំឡើងតម្លៃលក់ចេញ ក៏ទំនងជាមិនគ្រប់គ្រាន់ដើម្បីទប់ទល់ការថយចុះនៃប្រាក់ចំណេញរបស់គេ។ ក្រុមហ៊ុនអាចនឹងមានដំឡើងតម្លៃលើការលក់ផលិតផលរបស់ខ្លួននៅក្នុងឆ្នាំនេះ ប្រសិនបើការចំណាយលើការផលិតកើនឡើងលើសពីអ្វីដែលខ្លួនបានរំពឹងទុក។ នៅឆ្នាំនេះ គឺមិនសូវអំណោយផលទេសម្រាប់ទីផ្សាររបស់កូកាកូឡា ប៉ុន្តែក្រុមហ៊ុននេះ កំពុងខិតខំប្រឹងប្រែងធ្វើឱ្យបានល្អបំផុតតាមលទ្ធភាពដែលអាចធ្វើបាន។

ប្រាក់ចំណូលសុទ្ធប្រចាំត្រីមាសទី ៤ ឆ្នាំមុនរបស់ក្រុមហ៊ុន PepsiCo បានកើនឡើងជាង ១២% ដល់ជាង ២៥ពាន់លានដុល្លារ ខណៈដែលប្រាក់ចំណូលរបស់ Coca-Cola បានកើនឡើង ១០% ដល់ជាង ៩ពាន់លានដុល្លារ។

បើទោះបីជា មានការបារម្ភអំពីសម្ពាធលើប្រាក់ចំណេញនៅឆ្នាំ២០២២ក្តី ប៉ុន្តែ ក្រុមហ៊ុនផលិតភេសជ្ជៈលំដាប់ពិភពលោកទាំងពីរនេះ នៅតែមានក្តីរំពឹងថាតម្លៃភាគហ៊ុនរបស់ខ្លួននឹងបន្តកើនឡើងថែមទៀតនៅឆ្នាំ២០២២។ តួយ៉ាង កូកាកូឡារំពឹងថា តម្លៃភាគហ៊ុនខ្លួននឹងបន្តកើនឡើង៥% ទៅ៦% បន្ថែមទៀតនៅក្នុងមួយភាគហ៊ុន ធៀបនឹងឆ្នាំ២០២១៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២។*

**តើកត្តាអ្វីខ្លះជំរុញឱ្យតម្លៃទំនិញសកលលោកកើនឡើង ៥០% ជាកំណើនខ្ពស់បំផុតក្នុងរយៈពេល ២៧ ឆ្នាំចុងក្រោយនេះ?**



*ដោយ ខេមបូណូមីស*

ជាការពិតណាស់តម្លៃប្រេងឆៅ លោហៈធាតុ គ្រាប់ធញ្ញជាតិ និងទំនិញពាណិជ្ជកម្មអន្តរជាតិផ្សេងទៀតកំពុងកើនឡើងថ្លៃដល់ទៅ ៥០% ជាអត្រាកំណើនលឿនបំផុតគិតចាប់តាំងពីឆ្នាំ ១៩៩៥ មក។ ការកើនឡើងនេះ បានបង្កហានិភ័យនៃអស្ថិរភាពនយោបាយនៅក្នុងប្រទេសដែលពឹងផ្អែកខ្លាំងលើការនាំចូលទំនិញ។ តម្លៃទំនិញអន្តរជាតិកើនឡើងថ្លៃខ្លាំងដោយសារកត្តាសំខាន់ចំនួន ២ គឺកត្តាតម្រូវការកំពុងកើនឡើងខ្ពស់ ខណៈដែលសេដ្ឋកិច្ចបានងើបឡើងវិញពីជំងឺរាតត្បាតកូវីដ១៩ និងកត្តាផ្គត់ផ្គង់ទៅតាមតម្រូវការកំពុងត្រូវបានរារាំងដោយកត្តាភូមិសាស្រ្តនយោបាយដែលកំពុងតានតឹងកាន់តែខ្លាំងឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ទំនិញសំខាន់ៗចំនួន ២២មុខ គឺមានទំនិញចំនួន ៩ មុខហើយ បានកើនឡើងថ្លៃច្រើនជាង៥០% ក្នុងនោះផលិតផលកាហ្វេបានកើនឡើង៩១% និងកប្បាសកើនឡើង៥៨%និងអាលុយមីញ៉ូមកើនឡើង៥៣%។ យ៉ាងណាមិញ ស្របពេលដែលតម្រូវការប្រេងឆៅបានកើនឡើង ការវិនិយោគក៏ត្រូវបានរារាំងដោយការផ្លាស់ប្តូរទៅជា ប្រព័ន្ធសេដ្ឋកិច្ចដែលបញ្ចេញនូវកាបូនតិចផងដែរ។ ទន្ទឹមនឹងនេះ កង្វះកម្លាំងពលកម្មបានដាក់សម្ពាធកាន់តែខ្លាំងទៅលើតុល្យភាពរវាងការផ្គត់ផ្គង់និងតម្រូវការ។

តម្លៃទំនិញកើនឡើងបានជះឥទ្ធិពលដល់សង្វាក់ផ្គត់ផ្គង់ជាបន្តបន្ទាប់នៅក្នុងទីផ្សារ។ ជាក់ស្តែង រោងចក្រចម្រាញ់អាលុយមីញ៉ូ ដែលប្រើប្រាស់ថាមពលអគ្គិសនីយ៉ាងច្រើន ត្រូវបានបង្ខំឱ្យកាត់បន្ថយទិន្នផលដោយសារតម្លៃផលិតកម្មកើនឡើង ដែលបង្កើតឱ្យមានការខ្វះខាតលោហៈធាតុ។ ហើយការកើនឡើងតម្លៃឧស្ម័នធម្មជាតិក៏បានជំរុញឱ្យតម្លៃអាម៉ូញាក់ ដែលជាសមាសធាតុសំខាន់នៃជីកសិកម្មកើនឡើង ដែលវាជំរុញបន្តឱ្យតម្លៃគ្រាប់ធញ្ញជាតិកើនឡើងផងដែរ។

មូលនិធិរូបិយវត្ថុអន្តរជាតិបានប៉ាន់ប្រមាណថា កំណើនសេដ្ឋកិច្ចពិភពលោកនឹងធ្លាក់ចុះអស់០,៥% ។ ផ្អែកលើការកើនឡើងថ្លៃទំនិញទាំងនេះ ប្រទេសក្រីក្រអាចនឹងប៉ះពាល់ខ្លាំងជាងគេ។ សហរដ្ឋអាមេរិក និងប្រទេសផ្សេងទៀត កំពុងប្រញាប់ប្រញាល់ក្នុងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុជាការឆ្លើយតបទៅនឹងកម្រិតអតិផរណាកើនឡើងផងដែរ៕ *ដោយ ម៉ែន ខែមរៈ ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២។*

## ការខ្លាចរអារបស់អ្នកវិនិយោគទុនថារុស្ស៊ី ឈ្លានពានអ៊ុយក្រែន នាំឱ្យផ្សារភាគហ៊ុនពិភពលោកធ្លាក់ចុះ



*ដោយ campost.asia*

ក្រុមអ្នកវិនិយោគទុន ហាក់ដូចជាមានការខ្លាចរអាខ្លាំង នៅពេលលេចឮដំណឹងថា រុស្ស៊ី ជិតឈ្លានពានអ៊ុយក្រែន

ប៉ុន្តែនៅពេលមានសេចក្តីរាយការណ៍ថា រុស្ស៊ី មានកិច្ចប្រជុំជាមួយលោកខាងលិច ពាក់ព័ន្ធនឹងវិបត្តិអ៊ុយក្រែននោះ វាបានជួយធ្វើឱ្យអារម្មណ៍ពួកគេល្អឡើងវិញ ហើយរដ្ឋមន្ត្រីការបរទេសរុស្ស៊ី លោក សឺហ្គេ ឡាវរ៉ូវ បានលើកឡើងពីសម្តីប្រធានាធិបតីរុស្ស៊ី លោក វ្លាឌីមៀ ពូទីន ថា កិច្ចខិតខំការទូត នឹងបន្ត ដោយសារតែមានឱកាសចុះកិច្ចព្រមព្រៀង។

ស្ថាបនិកបង្កើតវេបសាយ Briefing.com បាននិយាយថា ការពិតកិច្ចពិភាក្សាបន្ថែមទៀត គឺជារឿងល្អ។ ហេតុដូច្នេះហើយ ភាពអវិជ្ជមានដែលមើលឃើញពីមុនរលាយបាត់ខ្លះអស់ នៅឡើយតែភាពមិនច្បាស់លាស់នៅលើទីផ្សារភាគហ៊ុនប៉ុណ្ណោះ។

ផ្សារភាគហ៊ុនអឺរ៉ុប ធ្លាក់ចុះយ៉ាងខ្លាំងក្នុងសប្តាហ៍នេះ ប៉ុន្តែប្រមូលបានខ្លះៗមកវិញនូវការខាតបង់នៅពេល ទិញ-លក់ថ្ងៃរសៀល ដោយសង្ឃឹមលើកិច្ចព្រមព្រៀងដោះស្រាយភាពតានតឹងនៅអ៊ុយក្រែន។ ផ្សារភាគហ៊ុនអង់គ្លេស FTSE 100 បានធ្លាក់ចុះ១,៧% ផ្សារភាគហ៊ុនដ៏សំខាន់នៅទីក្រុងប៉ារីស និងទីក្រុង Frankfurt របស់អាល្លឺម៉ង់ បានធ្លាក់ចុះ២%។ ការធ្លាក់ចុះរបស់ផ្សារភាគហ៊ុន FTSE 100 ដែលជាការធ្លាក់ចុះដ៏អាក្រក់បំផុតក្នុងរយៈពេល៣សប្តាហ៍ បានកើតមានឡើងបន្ទាប់ពីមានការធ្លាក់ចុះផ្សារភាគហ៊ុនអាស៊ី។ នៅទីក្រុងញូវយ៉ក ផ្សារភាគហ៊ុន Dow Jones បានធ្លាក់ចុះ០,៥% និងផ្សារភាគហ៊ុន Nasdaq ឡើងថ្លៃ០,៧%។ នៅផ្សារភាគហ៊ុន FTSE 100 និងផ្សារភាគហ៊ុន IAG ដែលជាម្ចាស់ក្រុមហ៊ុនអាកាសចរណ៍ British Airways និងក្រុមហ៊ុនអាកាសចរណ៍ Iberia បានធ្លាក់ចុះ៥,៦% ។ ភាគហ៊ុននៅតាមធនាគារធំៗ បានធ្លាក់ចុះចន្លោះពី៤ ទៅ៥%។ ក្រុមហ៊ុនដែលខាតធំជាងគេ គឺក្រុមហ៊ុនរុករករ៉ែរុស្ស៊ី Evraz ដែលតម្លៃភាគហ៊ុនបានធ្លាក់ចុះរហូតដល់២៩%។

តម្លៃប្រេងឡើងយ៉ាងឆាប់រហ័ស ក្នុងនោះប្រេងឆៅមានតម្លៃលើស៩៥ដុល្លារ ក្នុង១បារ៉ែល ធ្វើឱ្យមានការព្រួយបារម្ភពីអតិផរណាថ្មី។ ជាមួយនឹងតម្លៃប្រេងខ្ពស់ ខណៈដែលសេដ្ឋកិច្ចសកលងើបឡើងវិញ ក្រោយពីការបិទខ្ទប់ជំងឺ COVID-19 មាននូវការព្រួយបារម្ភថាសង្គ្រាម ឬការដាក់ទណ្ឌកម្មធ្ងន់ធ្ងរលើរុស្ស៊ី នឹងកាត់ផ្តាច់ការផ្គត់ផ្គង់ ធ្វើឱ្យតម្លៃប្រេងឆៅ ឡើងថ្លៃលើសពី ១០០ដុល្លារ ក្នុង១បារ៉ែល ដែលជាការឡើងថ្លៃមិនធ្លាប់មាន ចាប់តាំងពីឆ្នាំ២០១៤រហូតមក៕ *ដោយ ម៉ែន ខែមរៈ ប្រភព៖campost.asiaចេញផ្សាយថ្ងៃទី១៥ខែកុម្ភៈ ឆ្នាំ២០២២។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២២ ខែកុម្ភៈ ឆ្នាំ២០២២

- ធនាគារកណ្តាលនៃប្រទេសរុស្ស៊ីបានដំឡើងអត្រាគោលនយោបាយគោលរបស់ខ្លួន ទប់ទល់នឹងអតិផរណាខ្ពស់ជាប់ និងខណៈដែលប្រាក់រូប្លត្រូវបានវាយប្រហារដោយវិបត្តិអ៊ុយក្រែន
- កំណើននៃបំណុលរដ្ឋាភិបាលនៅក្នុងប្រទេសទួរគី នៅក្នុងខែធ្នូ ឆ្នាំ 2021

ថ្ងៃអង្គារ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២២

- អត្រាអតិផរណាប្រចាំឆ្នាំនៅក្នុងប្រទេសអ៊ីតាលីទំនងជាកើនឡើងដល់ 4.8%ក្នុងខែមករា ឆ្នាំ 2022 ពី 3.9 ភាគរយនៅក្នុងខែមុន
- អត្រានិកម្មភាព របស់អាហ្វ្រិកខាងត្បូងបានកើនឡើងដល់ 34.9% នៅក្នុងត្រីមាសទីបីនៃឆ្នាំ 2021 កើនឡើងពី 34.4%

ថ្ងៃពុធ ទី២៤ ខែកុម្ភៈ ឆ្នាំ២០២២

- សមតុល្យពាណិជ្ជកម្មរបស់ប្រទេសអាហ្សង់ទីនបានកត់ត្រាអតិរេក ក្នុងខែធ្នូ ឆ្នាំ 2021
- សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ក្នុងតំបន់អឺរ៉ូបានកើនឡើង 0.30%ក្នុងខែមករា ឆ្នាំ 2022

ថ្ងៃព្រហស្បតិ៍ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២២

- ធនាគារកណ្តាលកូរ៉េបានបង្កើនអត្រាមូលដ្ឋានរបស់ខ្លួន ដោយលើកឡើងពីការព្រួយបារម្ភអំពីអតិផរណាជាប់ និងបំណុលគ្រួសារកើនឡើង
- អត្រានិកម្មភាពនៅក្នុងប្រទេសប្រេស៊ីលបានធ្លាក់ចុះ ក្នុងរយៈពេលបីខែដល់ខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃសុក្រ ទី២៦ ខែកុម្ភៈ ឆ្នាំ២០២២

- សេដ្ឋកិច្ចអាឡឺម៉ង់បានពង្រីក 1.4% ក្នុងរយៈពេលបីខែចុងក្រោយនៃឆ្នាំ 2021
- អតិរេកពាណិជ្ជកម្មរបស់ប្រទេសម៉ិកស៊ិកបានធ្លាក់ក្នុងខែធ្នូ ឆ្នាំ 2021៕